# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៤៤ ព.ណ.អវិ.ឯ.ប្រក

នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជនពាណិជ្ជកម្ម
ចូល
លេខ 024 ន.អ.ស.ព.
ថ្ងៃទី 16 ខែ 5 ឆ្នាំ២០18
បញ្ជូន.......

# ប្រកាស
## ស្តីពី
## ការតម្កល់លក្ខន្តិកៈសមាគមអាជីវកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៩១ អនក្រ.បក ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រសួងពាណិជ្ជកម្ម
- ប្រកាសរួមលេខ១២១៧ សហវ.ប្រក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងពាណិជ្ជកម្ម
- តាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម។

## សម្រេច

**ប្រការ ១.-** សមាគមអាជីវកម្ម ជាសមាគមទាំងឡាយណា (រួមបញ្ចូលទាំងសភាពាណិជ្ជកម្មបរទេសនៅកម្ពុជា) ដែលធ្វើសកម្មភាព ឬប្រតិបត្តិការការងាររបស់ខ្លួន មានលក្ខណៈបម្រើដល់សកម្មភាពពាណិជ្ជកម្ម អាជីវកម្ម និងសេវាកម្ម ក្នុងគោលដៅមិនរកប្រាក់ចំណេញ។ សមាគមអាជីវកម្ម ជាសមាគមដែលធ្វើសកម្មភាពកំណត់ដោយច្បាប់ ឬបទបញ្ញត្តិផ្សេងៗ របស់រដ្ឋ។

**ប្រការ ២.-** សមាគមអាជីវកម្មទាំងអស់ ដែលធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែតម្កល់ទុកលក្ខន្តិកៈរបស់ខ្លួន នៅក្រសួងពាណិជ្ជកម្ម (នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន) បន្ទាប់ពីមានការចុះបញ្ជី ឬទទួលស្គាល់ជាផ្លូវច្បាប់ដោយស្ថាប័នមានសមត្ថកិច្ច ដើម្បីឱ្យសមាគមរបស់ខ្លួនជានាបានអំពីកិច្ចប្រតិបត្តិការអាជីវកម្មស្របច្បាប់។ ការតម្កល់លក្ខន្តិកៈសមាគមអាជីវកម្ម មិនតម្រូវឱ្យបង់កម្រៃសេវាសាធារណៈជូនរដ្ឋឡើយ ដូចមានចែងក្នុងកម្រងសេវាសាធារណៈ ក្នុងតារាងឧបសម្ព័ន្ធ នៃប្រកាសរួមរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាណិជ្ជកម្ម។

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារៈ (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61, Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469

**ប្រការ ៣.-** សំណុំបែបបទដើម្បីបំពេញសម្រាប់តម្កល់លក្ខន្តិកៈសមាគមអាជីវកម្ម មានដូចខាងក្រោម៖

- ពាក្យសុំតម្កល់លក្ខន្តិកៈ(មានគំរូស្រាប់) ចំនួន ០១ច្បាប់
- លក្ខន្តិកៈរបស់សមាគម ចំនួន ០១ច្បាប់
- កំណត់ហេតុអង្គសន្និបាតបង្កើតសមាគម (ច្បាប់ដើម) ចំនួន ០១ច្បាប់
- អត្តសញ្ញាណប័ណ្ណ ឬលិខិតឆ្លងដែនប្រធានសមាគម (ថតចម្លង) ចំនួន ០១ច្បាប់
- ឯកសារត្រូវបានចុះបញ្ជី ឬទទួលស្គាល់ជាផ្លូវការ (ថតចម្លង) ចំនួន ០១ច្បាប់
- រូបថត (ថតចំពីមុខ) ៤ X ៦ ចំនួន ០១សន្លឹក
- គំរូត្រា និងហត្ថលេខាប្រធានសមាគម
- លិខិតបញ្ជាក់ទីតាំងរបស់សមាគម(ថតចម្លង) ចំនួន ០១ច្បាប់

**ប្រការ ៤.-** ការតម្កល់ទុកលក្ខន្តិកៈសមាគមអាជីវកម្ម ត្រូវបានកំណត់ឱ្យតម្កល់នៅក្រសួងពាណិជ្ជកម្មតែ ០១លើក ប៉ុណ្ណោះ។ ក្នុងករណីសមាគមអាជីវកម្មមានការកែប្រែលក្ខន្តិកៈ អាសយដ្ឋាន ឬរចនាសម្ព័ន្ធនៃការគ្រប់គ្រងរបស់ខ្លួន សមាគមត្រូវស្នើសុំការតម្កល់លក្ខន្តិកៈឡើងវិញ ដោយភ្ជាប់មកជាមួយលក្ខន្តិកៈថ្មី ឬ ឯកសារពាក់ព័ន្ធថ្មី ឱ្យបាន ៣០ថ្ងៃ បន្ទាប់ពីមានការកែប្រែ។ សមាគមអាជីវកម្ម អាចផ្អាកសកម្មភាពរបស់ខ្លួន ដោយត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅក្រសួងពាណិជ្ជកម្ម។

**ប្រការ ៥.-** មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ត្រូវបានប្រគល់ភារកិច្ចឱ្យធ្វើការតាមដាននូវរាល់សកម្មភាព និងវឌ្ឍនភាពការងាររបស់សមាគមអាជីវកម្មទាំងឡាយ ដែលបានធ្វើការតម្កល់លក្ខន្តិកៈនៅក្រសួងពាណិជ្ជកម្ម។

**ប្រការ ៦.-** សមាគមអាជីវកម្មណាដែលបានចុះបញ្ជី ឬទទួលស្គាល់ជាផ្លូវច្បាប់ពីស្ថាប័នមានសមត្ថកិច្ច ហើយមិនបានធ្វើការតម្កល់លក្ខន្តិកៈនៅក្រសួងពាណិជ្ជកម្ម មិនត្រូវបានចាត់ទុកថាជាសមាគមអាជីវកម្មឡើយ។

**ប្រការ ៧.-** គ្រប់សមាគមអាជីវកម្មទាំងអស់ ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីវឌ្ឍនភាព នៃសកម្មភាពការងាររបស់ខ្លួន មកមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត ដែលសមាគមតាំងនៅជាទៀងទាត់ ដើម្បីងាយស្រួលក្នុងការជួយសម្របសម្រួល ឬមានវិធានការផ្សេងៗ ដើម្បីជួយទ្រទ្រង់ដល់សមាគម។

**ប្រការ ៨.-** ប្រកាសលេខ០៤៦ MOC/SM2013 ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៣ ស្តីពីការតម្កល់លក្ខន្តិកៈសមាគមអាជីវកម្ម ត្រូវទុកជានិរាករណ៍។

**ប្រការ ៩.-** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស.២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែមីនា ឆ្នាំ២០១៨

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន_សូរស័ក្តិ**

**ចម្លងជូន៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អង្គភាពប្រឆាំងអំពើពុករលួយ
- អាជ្ញាធរសវនកម្មជាតិ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី-ខេត្ត(ជូនជ្រាប)
- ដូចប្រការ ៩(ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ